# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....៣៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រង គ្រឿងសំអាង

***********

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីអំពីការគ្រប់គ្រង គុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និង សេវា

-បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្របក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០២

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងគ្រឿងសំអាងគ្រប់ប្រភេទ ដែលធ្វើអាជីវកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធានា គុណភាព និង សុវត្ថិភាពដល់អ្នកប្រើប្រាស់ ។

**មាត្រា ២.-**

គ្រឿងសំអាង គឺជាផលិតផល ដែលផ្សំឡើងដោយសារធាតុគីមី ជីវផលិតផល រុក្ខជាតិ ឬសិលាជាតិសំរាប់ ប្រើប្រាស់ក្នុងការ ការពារ ថែរក្សា សំអាត ឬ សំអាង ផ្នែកណាមួយនៃរាងកាយមនុស្ស ដើម្បី ឱ្យកាន់តែមានសោភ័ណភាព តាមវិធី ផាត់ លាប រិត ត្រាំ ម៉ាស្សា ឬ តាមវិធីណាមួយផ្សេងទៀត ។

**មាត្រា ៣.-**

គ្រឿងសំអាង មានជាអាទិ៍ផលិតផល :

- ប្រើលើសក់
- ប្រើលើស្បែក
- ប្រើលើក្រចក
- អនាម័យមាត់ ធ្មេញ និង ខ្លួនប្រាណគ្រប់ប្រភេទ
- ទឹកអប់និងគ្រឿងក្រអូបប្រហាក់ប្រហែល ។

## ជំពូកទី ២

## ប្រភេទ នៃគ្រឿងសំអាង

**មាត្រា ៤.-**

គ្រឿងសំអាងចែកជា២ប្រភេទ :

-ប្រភេទ១ : គ្រឿងសំអាង ផ្សំឡើងដោយសារធាតុគីមីដែលស្ថិតក្នុងបញ្ជីកំរិតកំណត់របស់ក្រសួងសុខាភិបាល និងគ្រឿងសំអាងដែលប្រើជុំវិញរង្វង់ភ្នែក បបូរមាត់ និងប្រើលើជាលិកាទន់ ។

បញ្ជីឈ្មោះសារធាតុសកម្ម និងសារធាតុរួមផ្សំ ព្រមទាំងកំរិតកំណត់របស់សារធាតុនិមួយៗដែលអនុញ្ញាតឱ្យប្រើក្នុងផលិតកម្មគ្រឿងសំអាង និង បញ្ជីឈ្មោះសារធាតុហាមឃាត់ក្នុងផលិតកម្មគ្រឿងសំអាង ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

-ប្រភេទ២ : គ្រឿងសំអាងដែលមិនស្ថិតក្នុងប្រភេទ១ ។

**មាត្រា ៥.-**

គ្រឿងសំអាងក្លែងបន្លំ ឬ ក្លែងក្លាយ គឺជា :

-គ្រឿងសំអាងដែលផលិតដោយគ្មានសារធាតុសកម្ម ឬសារធាតុផ្សំមិនគ្រប់ចំនួន ឬមិនត្រឹមត្រូវតាមសមាសធាតុផ្សំដែលផលិតករបានរៀបរាប់ដោយផលិតករបានចុះក្នុងឯកសារតម្កល់នៅក្រសួងសុខាភិបាល ពេលចុះ បញ្ជិកា ។

-គ្រឿងសំអាងដែលមានកំរិតជាតិសកម្មតិចជាង៨០% នៃកំរិតជាតិសកម្មកំណត់នៅក្នុងឯកសារឬលើប្រអប់ ។

## ជំពូកទី ៣
## បែបបទ និង លំនាំខំណត់ក្នុងការសុំចុះបញ្ជិកា

**មាត្រា ៦.-**

គ្រឿងសំអាងដែលនាំចូលសំរាប់ធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជាបាន លុះត្រាតែបានទទួលវិញ្ញាបនប័ត្របញ្ជិកាពីក្រសួងសុខាភិបាល ។ វិញ្ញាបនប័ត្របញ្ជិកាមានសុពលភាពរយៈពេល៥ឆ្នាំ ។

ចំពោះផលិតផលក្នុងស្រុកជាសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

**មាត្រា ៧.-**

ក្រសួងសុខាភិបាលមានសិទ្ធិដកហូតវិញ្ញាបនប័ត្របញ្ជិកាវិញ ក្នុងករណីគ្រឿងសំអាងនោះ :

ក-បានបង្កគ្រោះថ្នាក់ ដល់អ្នកប្រើប្រាស់

ខ-មានគុណភាពក្លែងបន្លំ ឬ មិនត្រឹមត្រូវតាមឯកសារផលិត ដែលបានតម្កល់នាពេលសុំចុះបញ្ជិកានៅក្រសួងសុខាភិបាល ។

## ជំពូកទី ៤

## បែបបទ អាជីវកម្ម និង ពាណិជ្ជកម្មគ្រឿងសំអាង

**មាត្រា ៨.-**

គ្រឿងសំអាងអាចតាំងលក់ក្នុងគ្រឹះស្ថានលក់ឱសថ ឬ គ្រឹះស្ថានលក់គ្រឿងសំអាង ដែលមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។ ចំពោះការលក់រាយនៅតាមទីកន្លែងនានា ដូចជាតូប ឬ រានលក់ឥវ៉ាន់តូចតាច មិនតម្រូវឱ្យមានការអនុញ្ញាតពីក្រសួងសុខាភិបាលទេ ប៉ុន្តែមន្ត្រីសុខាភិបាលអាចត្រួតពិនិត្យនូវផលិតផលទាំងនោះ ដើម្បីធានានូវសុវត្ថិភាពសាធារណៈ ។

**មាត្រា ៩.-**

ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសុខាភិបាល :

១-បែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំចុះបញ្ជិកាគ្រឿងសំអាង

២-បែបបទនិងល័ក្ខខ័ណ្ឌក្នុងការសុំបើកគ្រឹះស្ថានអាហរ័ណ នីហរ័ណគ្រឿងសំអាង

៣-បែបបទ និង ល័ក្ខខ័ណ្ឌ ក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មគ្រឿងសំអាង

## ជំពូកទី ៥

## សមត្ថកិច្ចក្នុងការគ្រប់គ្រង

**មាត្រា ១០.-**

ភ្នាក់ងារត្រួតពិនិត្យក្រសួងសុខាភិបាលដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិ :

-ចុះត្រួតពិនិត្យ និង ណែនាំការអនុវត្តន៍លិខិតបទដ្ឋាន ដែលពាក់ព័ន្ធនឹងគ្រឿងសំអាងនៅតាមគ្រឹះស្ថានអាហរ័ណ នីហរ័ណ និង អគារលក់គ្រឿងសំអាង

-ស្រង់យកគ្រឿងសំអាងគំរូសំរាប់ធ្វើការវិភាគគុណភាពក្នុងករណីចាំបាច់ រាប់ទាំងគ្រឿងសំអាងដែលផលិតក្នុងស្រុក

-ឃាត់ទុកបណ្តោះអាសន្នវត្ថុតាង ដែលមានការសង្ស័យជាបទល្មើស និងរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១១.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយ នឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២.-**

រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួលៈ</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- ឯកសារ-កាលប្បវត្តិ